# មេរៀនទី៧៧៖ បាណាបាសលើកទឹកចិត្តគ្រីស្ទបរិស័ទនៅក្រុងអាន់ទីយ៉ូក

**កិច្ចការ ១១៖១៩-២៦**

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/DtmANI3mt7Y

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/kMhdS-TmAuE

**គោលបំណង៖** គ្រីស្ទបរិស័ទថ្វាយបង្គំព្រះជាមួយគ្នា។

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ៩៥៖៦** *“មកចុះ ចូរយើងឱនកាយថ្វាយបង្គំទាំងអស់គ្នាចូរយើងលុតជង្គង់នៅចំពោះព្រះយេហូវ៉ាជាព្រះដ៏បង្កើតយើងខ្ញុំ។”*

**ចំរៀង** ( *យូធូបលីង* )៖

១. ក្បាល ស្មា ជង្គង់ ចុងជើង សរសើរព្រះអង្គ https://youtu.be/nh0Ekk87w4s
២. ខ្ញុំច្រៀងថ្វាយព្រះនៅក្នុងដួងចិត្តខ្ញុំ https://youtu.be/1th9e8PKFxs
៣. ខ្ញុំថ្វាយបង្គំទ្រង់ https://youtu.be/1C4guXZFdAw

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ក្បាល ស្មា ជង្គង់ ចុងជើង»

សម្ភារៈដែលត្រូវការ៖ ស្បែកជើង



១.ឲ្យកុមារចាប់ដៃគូពីរៗនាក់ហើយឈរទល់មុខគ្នា។ ( ពួកគេត្រូវឈរជាពីរជួរ )

២.ដាក់ស្បែកជើងមួយនៅចំកណ្ដាលកុមារទាំងពីរ។ ( ជាស្បែកជើងរបស់កុមារណាម្នាក់ក៏បាន )

៣.នៅពេលដែលគ្រូនិយាយថា “ក្បាល” កុមារទាំងអស់ ត្រូវប៉ះក្បាលរបស់ពួកគេ។ ដូចគ្នាបើលឺពាក្យថា “ស្មា” ប៉ះស្មា “ជង្គង់” ប៉ះជង្គង់។

៤.ប៉ុន្តែនៅពេលដែលគ្រូស្រែកថា “ចុងជើង” កុមារត្រូវដណ្ដើរស្បែកជើងដែលនៅចំកណ្ដាលដៃគូនីមួយៗ ។ ហើយនរណាដែលដណ្ដើមស្បែកជើងនោះបានគឺជាអ្នកឈ្នះ។

៥. នៅពេលដែលរកអ្នកឈ្នះឃើញហើយ សូមឲ្យពួកគេច្រៀង ក្បាលស្មាជង្គង់ចុងជើង។

៦.សូមឲ្យអ្នកឈ្នះទាំងអស់ចាប់ដៃគូពីរៗនាក់ហើយលេងល្បែងនេះបន្តទៀត រហូតរកបានអ្នកឈ្នះតែម្នាក់។ នៅពេលដែលរកឃើញអ្នកឈ្នះម្ដងៗ ពួកគេត្រូវច្រៀង ក្បាលស្មាជង្គង់ចុងជើង។

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា គ្រីស្ទបរិស័ទត្រូវតែថ្វាយបង្គំព្រះជាមួយគ្នា។

## ៤. ការណែនាំមេរៀន

សំឡេងយើងនឹងឮខ្លាំងជាង នៅពេលដែលយើងច្រៀងរួមគ្នា។ យើងមិនអាចក្លាយទៅជាគ្រីស្ទបរិស័ទដោយនៅតែឯងបានទេ។ យើងត្រូវការគ្រីស្ទបរិស័ទផ្សេងទៀត ដើម្បីលើកទឹកចិត្តយើង និងជួយយើងឲ្យរីកចម្រើន។ ការលើកទឹកចិត្តអ្នកដទៃក៏ជួយយើងឲ្យរីកចម្រើនដែរ។ ថ្ងៃនេះ យើងនឹងរៀនអំពីព្រះមានព្រះហឫទ័យរីករាយ ពេលដែលគ្រីស្ទបរិស័ទលើកទឹកចិត្តគ្នាទៅវិញទៅមក ហើយការថ្វាយបង្គំព្រះជាមួយគ្នា។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីររបស់យើងថ្ងៃនេះបានមកពីព្រះគម្ពីរកិច្ចការ។ នៅក្នុងសាច់រឿងរបស់យើងមានមនុស្សជាច្រើន ដែលបានជឿលើព្រះយេស៊ូវត្រូវបានបែកបាក់ចេញពីគ្នា។ ការនេះបានកើតឡើងដោយសារអ្នកដើរតាមព្រះយេស៊ូវត្រូវគេបៀតបៀន និងសម្លាប់នៅក្រុងយេរូសាឡិម។ អ្នកដើរតាមព្រះយេស៊ូវជាច្រើននាក់បានចាកចេញពីក្រុងយេរូសាឡិម ហើយផ្លាស់ទៅទីក្រុងនានាដែលមានសាសន៍ដទៃជាច្រើនដូចជាភេនីស គីប្រុស និងអាន់ទីយ៉ូក។ សាសន៍ដទៃគឺជាមនុស្សដែលមិនមែនជាជនជាតិយូដា។

ជាធម្មតា ជនជាតិយូដាមិនបរិភោគជាមួយ ឬនិយាយជាមួយសាសន៍ដទៃទេ ប៉ុន្តែពេត្រុសបានប្រាប់ពួកគេថា ព្រះស្រឡាញ់មនុស្សទាំងអស់ សូម្បីតែសាសន៍ដទៃក៏ដោយ។ ដូច្នេះពួកសិស្សរបស់ព្រះយេស៊ូវបានប្រកាសដំណឹងល្អដល់គ្រប់គ្នា ទាំងសាសន៍យូដា និងសាសន៍ដទៃដែរ។ ពួកគេស្រឡាញ់ព្រះហើយស្រឡាញ់គ្នាទៅវិញទៅមក ទោះបីជាពួកគេមានជាតិសាសន៍ខុសគ្នាក៏ដោយ។ ពួកគេបានថ្វាយបង្គំព្រះជាមួយគ្នា ហើយពោរពេញដោយអំណរ។ នៅក្រុងអាន់ទីយ៉ូក អ្នកដើរតាមព្រះយេស៊ូវត្រូវបានគេហៅថាជា "គ្រីស្ទបរិស័ទ" ជាលើកដំបូង។ "គ្រីស្ទបរិស័ទ" សំដៅលើប្រជាជនរបស់ព្រះគ្រីស្ទ។

ពេលដំណឹងល្អអំពីព្រះយេស៊ូវត្រូវបានផ្សាយដល់ជនជាតិយូដា និងសាសន៍ដទៃក្នុងក្រុងយេរូសាឡិម ពួកសាវ័កបានបញ្ជូនបាណាបាសទៅក្រុងអាន់ទីយ៉ូក។ បាណាបាសពេញដោយអំណរពេលបានឃើញជនជាតិយូដា និងសាសន៍ដទៃថ្វាយបង្គំព្រះជាមួយគ្នា ដោយសារគាត់ដឹងថា ព្រះស្រឡាញ់មនុស្សទាំងអស់។ គាត់បានលើកទឹកចិត្តពួកគេឲ្យរក្សាភាពស្មោះត្រង់ចំពោះព្រះនៅក្នុងចិត្ត។ ឈ្មោះ "បាណាបាស" មានន័យថា "អ្នកលើកទឹកចិត្ត" ។

ពេលយើងថ្វាយបង្គំព្រះជាមួយគ្នា យើងអាចក្លាយជាអ្នកលើកទឹកចិត្តដ៏អស្ចារ្យដូចបាណាបាសដែរ។ ជាទូទៅយើងតែងគិតថា ការថ្វាយបង្គំជាពេលដែលយើងកំពុងច្រៀងចម្រៀងថ្វាយព្រះ ប៉ុន្តែការថ្វាយបង្គំមានន័យច្រើនជាងនោះទៅទៀត។ ការថ្វាយបង្គំគឺគ្រប់ពេលដែលយើងនិយាយជាមួយព្រះ ស្តាប់បង្គាប់ព្រះ ឬរស់នៅតាមរបៀបដែលព្រះចង់ឲ្យយើងរស់នៅ។ យើងត្រូវលើកទឹកចិត្តគ្នាទៅវិញទៅមកថ្វាយបង្គំព្រះជារៀងរាល់ថ្ងៃសំរាប់ជីវិតរបស់យើង! វាពិបាកក្នុងការរស់នៅជាគ្រីស្ទបរិស័ទ ពេលដែលយើងរស់នៅតែឯង។ តែយើងកាន់តែរឹងមាំពេលដែលយើងនៅជាមួយគ្នា លើកទឹកចិត្តគ្នាទៅវិញទៅមក! ព្រះសព្វព្រះទ័យ ពេលដែលយើងថ្វាយបង្គំទ្រង់ជាមួយគ្នា ហើយលើកទឹកចិត្តគ្នាទៅវិញទៅមក!

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាអ្នកដើរតាមព្រះយេស៊ូវជាច្រើននាក់ចាកចេញពីក្រុងយេរូសាឡិម? *( គ្រីស្ទបរិស័ទត្រូវបាន គេបៀតបៀន និងសម្លាប់នៅក្រុងយេរូសាឡិម)*

២. តើសាវ័កណាខ្លះបានបញ្ជូនទៅក្រុងអាន់ទីយ៉ូក ដើម្បីមើលរបៀបដែលដំណឹងល្អកំពុងត្រូវបានផ្សព្វផ្សាយនៅក្រុងអាន់ទីយ៉ូក? *(បាណាបាស)*

៣. តើអ្នកនៅក្រុងអាន់ទីយ៉ូកហៅអ្នកដើរតាមព្រះគ្រីស្ទថាជាអ្វី? *(គ្រីស្ទបរិស័ទ)*

៤. តើការថ្វាយបង្គំជាអ្វី? *(ច្រៀងថ្វាយព្រះ និយាយជាមួយព្រះ ស្តាប់ព្រះ រស់នៅតាមរបៀបដែលព្រះចង់ឱ្យយើងរស់នៅ)*

៥. តើអ្នកអាចលើកទឹកចិត្តអ្នកឯទៀតឲ្យថ្វាយបង្គំព្រះយ៉ាងដូចម្តេច? *(ឱ្យកុមារឆ្លើយ)*

## **៧. ល្បែងកំសាន្ត «ច្រៀងចម្រៀងដោយខ្លួនឯងដោយប្រើឧបករណ៍ច្នៃប្រឌិត»**



១. ចែកកុមារជា ៤ ឬ ៥ ក្រុម

២. ប្រាប់កុមារថា ពួកគេអាចប្រើរបស់របរទាំងអស់ដែលអាចរកបាន ដើម្បីធ្វើជា ឧបករណ៍ភ្លេង (ដុំថ្ម២ដុំសម្រាប់ដំលើគ្នា ឈើសម្រាប់គោះលើតុ ។ល។) ហើយ ជ្រើសរើសចម្រៀងមួយបទ ច្រៀងជាមួយគ្នា។

៣. ដើម្បីឈ្នះល្បែងនេះបាន ក្រុមនីមួយៗត្រូវតែមានគំនិតច្នៃប្រឌិត ក្នុងការបង្កើតឧបករណ៍សរសើរតម្កើងព្រះ។

៤. ក្រុមនីមួយៗមានពេល ៥នាទីក្នុងការបង្កើតឧបករណ៍ និងសមក្នុងការសរសើរតម្កើងព្រះជាមួយគ្នា។

៥. គ្រូនឹងសម្រេចថា ក្រុមមួយណាធ្វើបានល្អជាងគេ ហើយឲ្យក្រុមទាំងអស់ច្រៀងតាមក្រុមដែលឈ្នះ។

៦.បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះនឹងសព្វព្រះទ័យ នៅពេលដែលគ្រីស្ទបរិស័ទថ្វាយបង្គំព្រះជាមួយគ្នា។

## **៨. ខគម្ពីរចងចាំ**

**ទំនុកដំកើង ៩៥:៦** *"មកចុះ ចូរយើងឱនកាយថ្វាយបង្គំទាំងអស់គ្នាចូរយើងលុត ជង្គង់នៅចំពោះព្រះយេហូវ៉ាជាព្រះដ៏បង្កើតយើងខ្ញុំ។"*

## **៩. ហត្ថកម្ម «យើងថ្វាយបង្គំព្រះជាមួយគ្នា»**

សម្ភារៈដែលត្រូវការ៖ ក្រដាសពណ៌ កន្ត្រៃ កាវបិត ហ្វឺត



១. ឱ្យកុមារម្នាក់ៗដានដៃរបស់ពួកគេនៅលើក្រដាសពណ៌ ហើយកាត់វាចេញ។ គូរភ្នែក និងមាត់នៅលើក្រដាសដៃដែលបានកាត់ហើយនោះ។

២. បន្ទាប់មក គេអាចគូរដើម និងស្លឹក ហើយកាត់វាចេញ។ បិតដៃនិងស្លឹកនៅលើដើម។ (បើសិនក្មេងពិបាកធ្វើ គ្រូអាចរៀបចំដើម និងស្លឹកមុនពេលបង្រៀន។)

៣.គ្រូគួរប្រមូលដៃទាំងអស់ ហើយបិតវានៅលើជញ្ជាំង។ គ្រូត្រូវសរសេរ និង បិតពាក្យថា "យើងថ្វាយបង្គំព្រះជាមួយគ្នា" នៅ ខាងលើ ឬ ខាងក្រោម។



៤.សូមរំឭកកុមារថាព្រះសព្វព្រះទ័យពេលយើងលើកទឹកចិត្តទៅវិញទៅមក ហើយថ្វាយបង្គំព្រះជាមួយគ្នា។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
បាណាបាសបានដឹងថាពេលមនុស្សនៅតែឯងជំនឿមិនរីកចម្រើនទេ ។ យើងទាំងអស់គ្នាត្រូវការការលើកទឹកចិត្តពីគ្រីស្ទបរិស័ទដទៃទៀត។ មិត្តភាពរបស់គ្រីស្ទបរិស័ទដ៏រឹងមាំនឹងជួយឱ្យទំនាក់ទំនងរបស់អ្នកជាមួយ ព្រះយេស៊ូវកាន់តែរឹងមាំ! តើក្នុងជីវិតរបស់អ្នក មាននរណាដែលដូចបាណាបាស ដែលអ្នកអាចងាកមករកការលើកទឹកចិត្តបានដែរឬទេ? តើអ្នកដូចបាណាបាសចំពោះអ្នកណាខ្លះ ដែលអ្នកបានលើកទឹកចិត្តពួកគេជាប្រចាំ? សូមអធិស្ឋានសម្រាប់ពួកគេក្នុងសប្តាហ៍នេះ ដើម្បីឲ្យពួកគេនឹងបន្តរីកចម្រើននៅក្នុងព្រះគ្រីស្ទ។